**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៥៧. សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និង ការប្រមូលទិន្នន័យនៃការទទួលបានសេវាកម្មរបស់ជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០០/១៦០ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មមាត្រា៤, ១០ និងមាត្រា១៣ នៃព្រះរាជក្រឹត្យលេខនស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៧៦អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ៩២អនក្រ.បកចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលមាត្រា៧ថ្មី ជំពូកទី៥ នៃអនុក្រឹត្យលេខ ១០០ អនក្រ/បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៥និងច្របាច់បញ្ចូលជំពូកទី១០ និងជំពូកទី១១នៃអនុក្រឹត្យលេខ៧៦អនក្រ.បកចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បកចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បកចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ

- យោងតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរមីន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលនិធិជនពិការ

# សម្រេច

**ប្រការ១៖** ត្រូវបានកែសម្រួលសមាសភាពក្រុមការងារគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងប្រមូលទិន្នន័យនៃការទទួលបានសេវាកម្មរបស់ជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធនានា លើសកម្មភាពកិច្ចសង្គ្រោះជនពិការដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ក្នុងនាមកម្ពុជាជារដ្ឋភាគីអនុសញ្ញាអូតាវ៉ា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ព្រុំ សុខមង្គល** | អគ្គលេខាធិការ អាជ្ញាធរមីន | ប្រធាន |
| ២-ឯកឧត្តម **ប្រាក់ សុខឃួរ** | អគ្គលេខាធិការរង អាជ្ញាធរមីន | អនុប្រធាន |
| ៣-លោក **ជួរ រតនៈ** | អគ្គនាយករងនៃក្រសួង ស.អ.យ. និងជានាយកមូលនិធិជនពិការ | អនុប្រធាន |
| ៤-លោក **ម៉ៅ ប៊ុនញ្ញាត្ត** | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| ៥-លោក **ទីម ដារ៉ា** | ប្រធាននាយកដ្ឋានផែនការស្ថិតិនិងសរុប ក្រសួង ស.អ.យ. | សមាជិក |
| ៦-លោក **ញ៉ែម ចាន់ណេរ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួង ស.អ.យ. | សមាជិក |
| ៧-លោក **ឡៅ ម៉េង** | ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ ក្រសួង ស.អ.យ. | សមាជិក |
| ៨-លោក **រៀម សារ៉ាត** | ប្រធានផ្នែកសុខុមាលភាព និងស្តារលទ្ធភាពពលកម្មជនពិការ អ.ក.ស.ជ. | សមាជិក |
| ៩-លោក **នី ញ៉ៃ** | អនុប្រធាននាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន | សមាជិក |
| ១០-លោក **ម៉ុម សុត្ថារ៉ា** | នាយករងមូលនិធិជនពិការ ក្រសួង ស.អ.យ. | សមាជិក |
| ១១-លោក **ខួន មនោរតេឡា** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ចសង្គម និងគ្រប់គ្រងទិន្នន័យ អាជ្ញាធរមីន | សមាជិក |
| ១២-លោក **លាង សំអុល** | ប្រធានការិយាល័យសេវាសាធារណៈ និងគោលនយោបាយមូលនិធិជនពិការ | សមាជិក |
| ១៣-លោក **តន់ សារ៉ា** | ប្រធានការិយាល័យទិន្នន័យអាជ្ញាធរមីន | សមាជិក |
| ១៤-លោក/លោកស្រីប្រធានមជ្ឈមណ្ឌលស្តារកាយសម្បទារាជធានី/ខេត្តទាំង១១រូប | | សមាជិក |
| ១៥-លោក **ញ៉ែម ធុល** | ប្រធានការិយាល័យសេវាកម្មអាជ្ញាធរមីន | លេខាធិការ |

**ប្រការ២៖** ក្រុមការងារនេះ មានតួនាទី និងភារកិច្ចដូចតទៅ៖

- ប្រមូលព័ត៌មានទិន្នន័យពីក្រសួង/ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
- ចងក្រង និងបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

- ចែករំលែក និងផ្សព្វផ្សាយរបាយការណ៍ ដើម្បីសុំការពិគ្រោះយោបល់ និងទទួលបានធាតុចូលបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធ
- រៀបចំរបាយការណ៍ដំបូង និងបន្តបន្ទាប់ស្តីពីកិច្ចសង្គ្រោះជនពិការដោយសារមីន និងស.ផ.ស. ជូនថ្នាក់ដឹកនាំអាជ្ញាធរមីន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និងមូលនិធិជនពិការ ដើម្បីពិនិត្យកែសម្រួលសម្រាប់ត្រៀមចូលរួមកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធ
- ចូលរួមប្រជុំជាប្រចាំ និងទៀងទាត់តាមការអញ្ជើញរបស់ប្រធាន

**ប្រការ៣៖** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការអាជ្ញាធរមីន និងសាមីខ្លួន ដូចមានចែងក្នុងប្រការ០១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ . ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
- រាជកិច្ច
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ